N° 8

Reçu le 16-11-51

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែសីហា លេខ ៨

ព. ស. ២៤៩៤ — គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|

ពុទ្ធសាសនានឹងគ្រឹស្តសាសនា (សន្និសីទ
លោកវេជ្ជបណ្ឌិតមីគូត៍) (តមក)... លោកភ៉ាយ – ប៊ុក ........... ៥៦៤
ពន្លឺអាស៊ីទ្វីប (តមក)............ លោកភ៉ាយ – ប៊ុក ........... ៥៧០
យភាវាសធម្មកថា ................ ព្រះគ្រូមុនីសោភ័ណ សេខ - នាង. . ៥៧៥

ផ្នែកអក្សរសាស្ត្រ

ការបណ្ដុះនិស្ស័យ (តមក)........ ព្រះមហាខត្តមវិជ្ជា ប៊ុង – ម៉ម .... ៥៨៤
អីឡេណា – ស័មប៉្យណា (តមក)..... លោកផេង – ជ្រីវ ........... ៥៩៣
រឿងសាមកុក (តមក)............ ឧកញ៉ា នូ – កន ........... ៦០១
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).. ឧកញ៉ា ឈឹម - ក្រសេម ..... ៦១៤
រឿងអារក្សថ្លែងរឿងម្ដៃប្រាំ (តមក).... លោកសាង - សាភ៉ត ....... ៦១៩

កំណត់ទីនប្រវត្តិការណ៍

ដំណើរ មកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត
គុណបាលបិយសេន ម៉ាល៉ាល័ះសេកេរះ (តមក) ពុទ្ធសាសនបណ្ឌិត្យ......... ៦២៨

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៤៥ រ.០០

ឃរាវាសធម្មកថា

# ព្រះគ្រូមុនីសោភ័ណ សេខ-តាំង សាស្ត្រាចារ្យ

## នៅសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

ទេសនាផ្សាយវិទ្យុឃោសនា នៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែអស្សុជ
ឆ្នាំកុរឯកស័ក ព.ស. ២៤៩ (២៩-១-៤៧)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយគោរព) ។

វេលានេះ អាត្មាភាពនឹងសំដែងអំពីឃរាវាសធម៌ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា នៃពុទ្ធសាសនិកជនតទៅ ។

មុននឹងសំដែងញែកជាមេមាតិកានៃធម៌នេះ សូមអធិប្បាយពាក្យថា ឃរាវាសធម៌សិន ។

ឃរាវាសធម៌ ប្រែថា "ច្បាប់សម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ" ។

ការនៅជាប់ទាក់ទងគ្នា ដោយស្វាមី ភរិយា-មាតា-បិតា-បុត្រធីតា របស់បុរសស្ត្រីអ្នកនៅគ្រប់គ្រងផ្ទះ ហៅថាឃរាវាស ដែលនៅរួមគ្នាជាសង្គមមួយៗ រមែងមានការប៉ះទង្គិចប្រេះស្រាំជាធម្មតា ប្រៀបដូចចានមួយរាវនៅក្នុងទីជាមួយគ្នា រមែងរណ្តំគ្នា ប៉ុន្តែគង់មានប្រដាប់សម្រាប់ទប់កុំឲ្យប៉ះទង្គិចគ្នាបាន ។

ឯពានកាលបើមានវត្ថុអ្វីមួយ ជាទ្រនាប់សម្រាប់ទ្រុំអបស្តូបហើយ គេអាចដឹកនាំទៅកាន់ទីជិត-ឆ្ងាយបានដោយស្រួលតាមប្រាថ្នា ឥតមានរណ្តំគ្នាឬប្រេះស្រាំបែបធាឡើយ មានគួរនាយ៉ាងណាមិញ មានគួរនាដូចជាបុគ្គលអ្នកគ្រប់គ្រងផ្ទះ ក៏ត្រូវមានឃរាវាសធម៌នេះជាទ្រនាប់ គឺជាច្បាប់សម្រាប់ប្រតិបត្តិ មិនឲ្យឃ្លាងគំនិតគ្នា ដើម្បីឲ្យកើតសេចក្តីសុខស្រួលក្នុងសង្គមនីមួយៗ ដូច្នោះដែរ ។

ឃរាវាសធម៌នោះ តាមច្បាប់ព្រះពុទ្ធសាសនាមានច្រើនយ៉ាង ។ ក្នុងទីនេះ ខ្ញុំសុំថ្លែងតែឃរាវាសធម៌ ៤ យ៉ាង ដែលមាននៅក្នុងគម្ពីរព្រះសុត្តន្តបិដក ភាគ ៣០ ត្រង់យក្ខសំយុត្ត ។

ឃរាវាសធម៌ ៤ យ៉ាងនោះ គឺ :

១ – សច្ចៈ: ការទៀងត្រង់

២ – ទមៈ: ការទូន្មាន

៣ – ខន្តិ ការទប់ចិត្ត

៤ – ចាគៈ: ការបរិច្ចាគ ។

សូមអធិប្បាយមួយម្តងៗ ឲ្យសមគួរដល់ភាពជាឃរាវាសធម៌ ដើម្បីជាសាធារណប្រតិបត្តិតទៅ ។

**សច្ចៈ** – ការធ្វើកាយ - វាចា - ចិត្តឲ្យទៀងត្រង់ ស្មោះចំពោះដល់គ្នានិងគ្នា ហៅថាសច្ចៈៗនេះ បានដល់ភាពនៃបុគ្គលជាអ្នកទៀងត្រង់និង

សំឡាញ់ មិនទ្រុស្តមិត្រមានចិត្តស្មោះត្រង់នឹងគ្នា, – ទៀងត្រង់ចំពោះកាលវេលា ដែលជាពេលត្រូវចូលត្រូវចេញ, – ទៀងត្រង់ចំពោះកិច្ចការដែលជាមុខក្រសួងខ្លួនត្រូវធ្វើ ។ ដូចជាទាសកម្មករត្រូវទៀងត្រង់នឹងចៅហ្វាយនាយៗ ត្រូវទៀងត្រង់នឹងទាសកម្មករ, ស្វាមីនឹងភរិយាត្រូវត្រង់នឹងគ្នាកប់រក្សាមិនក្បត់ចិត្តគ្នា, មាតា-បិតានឹងបុត្រ-ធីតា ត្រូវទៀងត្រង់នឹងគ្នា, ប្រជាជនត្រូវទៀងត្រង់គោរពកោតក្រែងចំពោះរាជការរដ្ឋាភិបាល ។ ចំណែករាជការរដ្ឋាភិបាល ត្រូវទៀងត្រង់នឹងប្រជាជនដែលជាពលរដ្ឋ ដោយការគ្រប់គ្រងរក្សាគ្រប់កាលវេលា ដូចជាមាតា-បិតាបីបាច់រក្សាបុត្រ-ធីតាដូច្នោះ ឲ្យមានការទំនុកទុកចិត្តទៅវិញទៅមក, ការទៀងត្រង់ទាំងអស់នេះ ហៅថាសច្ចៈ ។

សច្ចៈនេះ ជាគុណការធ្វើបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ឲ្យជាទីគោរពកោតក្រែងនៃជនដទៃ ដូចសេចក្តីដែលពោលមកនេះ ហេតុនោះទើបឈ្មោះថា ឃរាវាសធម៌ ដោយប្រការដូច្នេះ ។

២ ទម – ការហ្វឹកហ្វឺនទូន្មានខ្លួនឲ្យប្រាសចាកភ័យអន្តរាយ ឲ្យប្រាសចាកការឆ្គាំឆ្គងថោកទាប ដើម្បីឲ្យមានបែបបទសណ្ដាប់ធ្នាប់ ចរិយាល្អ ឈ្មោះថាទមៈៗ នេះ លោកចែងប្រាប់សេចក្តីផ្សេងៗ គ្នា គឺដូចកាលលោកប្រាប់ថាបានដល់ឥន្ទ្រិយសំវរៈ "ការសង្រួមឥន្ទ្រិយ", ចួនកាលថាបានដល់វិបស្សនាបញ្ញា "ប្រាជ្ញាជាគ្រឿងឃើញច្បាស់" ។ តែក្នុងទីនេះ

សំដៅយកការហាត់ពត់កាយ-វាចា-ចិត្ត ឲ្យមានចរិយាល្អ ស្លូតសុភាព រាបសា កុំឲ្យប្រព្រឹត្តទុច្ចរិតផ្សេងៗ កុំឲ្យប្រព្រឹត្តនូវអបាយមុខដែលជាផ្លូវនាំឲ្យវិនាស ខិលខូចប្រឡៀសប្រើសដើរលេងល្បែងផ្សេងៗ ដោយប្រែកល្ហកឥតប្រយោជន៍ ។

មួយទៀតបុគ្គលត្រូវបង្ហឹកខ្លួន ឲ្យបានសមគួរដល់វ័យទាំង ៣ គឺវ័យទី ១ ត្រូវខំប្រឹងសង្វាតរករៀនវិជ្ជា កុំបណ្ដោយឲ្យវ័យទី ១ កន្លងទៅឥតប្រយោជន៍, វ័យទី ២ ត្រូវចុះដៃធ្វើការស្វែងរកទ្រព្យសម្បត្តិឲ្យបានទាន់វ័យនៅមានកម្លាំង កុំខ្ជិលទ្រមក់ដំអក់ទ្រមែន, វ័យទី ៣ ត្រូវខ្មីខ្មាស្រាវរកធម៌ មកប្រតិបត្តិបម្រុងប្រាណឲ្យបានជាទីពឹងទៅក្នុងលោកខាងមុខ; ការទូន្មានខ្លួនក្នុងវ័យទាំង ៣ នេះ ហៅថាទមៈ ។

មែនពិត ពួកមនុស្សគ្រាន់តែក្នុងប្រទេសណា ជំនាន់ណាក៏ដោយ បើប្រាសចាកធម៌ទមៈនេះហើយ មិនយូរប៉ុន្មានទេ ពួកមនុស្សនៅក្នុងប្រទេសនោះ ជំនាន់នោះ មុខជានឹងវិយោគគ្មានសណ្ដាប់ធ្នាប់ ជាហេតុឲ្យថោកជាតិ ទាបវាសនាថយចុះសស្រឹមទៅតាមលំដាប់ រហូតដល់បានឈ្មោះថា ជាមនុស្សកំពេលឬមនុស្សព្រៃ អំពីសំណាក់លោកអ្នកប្រាជ្ញគ្រប់សម័យ ។

ទមៈនេះ ជាគុណធ្វើមនុស្សថោកទាប ឲ្យបានខ្ពង់ខ្ពស់មានសណ្ដាប់ធ្នាប់ចរិយាល្អ អាចក្រៃឡើងជាតិ កែវាសនា ឲ្យក្លាយទៅជាអរិយៈទី ១

ក្នុងអរិយៈទាំង ៤ ពួក គឺ: អាចារារិយៈ (ខ្ពង់ខ្ពស់មារយាទ) ១, ទស្សនារិយៈ(ខ្ពង់ខ្ពស់ដោយការឃើញ)១, លិង្គារិយៈ(ខ្ពង់ខ្ពស់ភេទ)១, បដិវេធារិយៈ (ខ្ពង់ខ្ពស់ដោយការត្រាស់ដឹង) ១ ៗ អ្នកដែលបានដល់នូវភាពដ៏ថ្លៃថ្លាយ៉ាងនេះ ក៏ដោយមានទមធម៌នៅប្រចាំក្នុងចិត្ត ហេតុនោះទើបឈ្មោះថា យកក់សធម៌ ដោយប្រការដូច្នេះ ៗ

បីតិ – ការទប់ចិត្តចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើតលោភៈ ទោសៈ មោហៈ ហៅថាបីតិ ឬហៅថាខន្តិ (សេចក្ដីអត់ធន់) ក៏បាន ៗ

ការអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើតលោភៈនោះ បានដល់ការអត់ធន់ចំពោះចំណង់ផ្សេងៗ ដែលកើតឡើងក្នុងទ្វារទាំង ៦ មានការអត់ធន់មិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬសេចក្ដីស្រេកឃ្លាននោះៗ ព្រោះបុគ្គលអ្នកមិនចេះអត់ធន់នឹងចំណង់ ឬសេចក្ដីស្រេកឃ្លានហើយ មុខជានឹងលួចឆក់ដណ្ដើមបំបាត់ប្រពន្ធទ្រព្យសម្បត្តិរបស់គេ, កាលបើប្រព្រឹត្តទុច្ចរិតដូច្នោះ រមែងចួបប្រទះនឹងសេចក្ដីទុក្ខព្រួយ ដែលជាផលរបស់ទុច្ចរិតនោះៗ មានត្រូវទោសជាប់គុកជាប់ច្រវាក់ជាដើម ៗ បុគ្គលឯណា ចេះទប់ចិត្តមិនរវះរវាមហួសពេក បុគ្គលនោះឯងតែងចួបប្រទះនឹងសេចក្ដីសុខ-ចំរើន ៗ ការអត់ធន់យ៉ាងនេះ ហៅថាអត់ធន់ចំពោះលោភៈ ៗ

ការអត់ធន់ចំពោះទុក្ខ ដែលជាហេតុឲ្យកើតទោសៈនោះ បានខាងការអត់ធ្មត់នឹងពាក្យបរប្បក់ដែលបុគ្គលដទៃស្ដីថា ត្មះតិះដៀល ឬអត់ធន់

ចំពោះបុគ្គលដទៃទៀតទៀន ដែលជាហេតុឲ្យកើតទោសៈ ដូចនៅក្នុងសង្គមនិមួយៗ គឺស្វាមីនិងភរិយា ត្រូវមានសេចក្ដីអត់ធុនទៅវិញទៅមករក្សា មាតាបិតានិងបុត្រធីតា ទាសកម្មករនិងចៅហ្វាយនាយ, ប្រជាជននិងរាជការរដ្ឋាភិបាល ក៏ត្រូវមានសេចក្ដីអត់ធន់ មានការគោរពរាប់អានគ្នាជាទីទំនុកទុកចិត្តគ្នាទៅវិញទៅមក យ៉ាងនេះជាដើម ហៅថាការអត់ធន់ចំពោះទោសៈ ។

ឯសេចក្ដីអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើតមោហៈនោះបានដល់ការអត់ទ្រាំនឹងទុក្ខវេទនាលំបាកផ្សេងៗ ដែលកើតឡើងក្នុងកាយនិងចិត្ត មិនឲ្យលុះក្នុងអំណាចទុក្ខវេទនា ហើយទៅប្រព្រឹត្តទុច្ចរិតឡើយ ។ សូម្បីការអត់ទ្រាំនឹងទុក្ខវេទនាក្នុងវេលាឈឺចាប់នោះសោតក៏ជាហេតុជួយឧបត្ថម្ភឲ្យមានសតិសម្បជញ្ញៈ គឺសេចក្ដីរឭកនិងសេចក្ដីដឹងខ្លួនដែលជាគុណវិសេសគួរឲ្យមានក្នុងចិត្តគ្រប់កាលទាំងពួង ។ ពុំនោះសោតក្នុងវេលាមានព្យាធិ ដែលជាហេតុឲ្យដល់មរណៈ ក៏ត្រូវតែមានការអត់ធន់ខានមិនបាន ព្រោះថា បុគ្គលណាកាលបើបណ្ដោយឲ្យមោហៈគឺសេចក្ដីវង្វេងកើតឡើង និងធ្វើការអ្វី ក៏ធ្វើទាំងកំពេលទាំងងងឹត, គិតការអ្វីក៏គិតទាំងបំពាន បុគ្គលនោះរមែងទទួលផលនៃសេចក្ដីទុក្ខដោយពិត ។

បុគ្គលឯណាអត់ទ្រាំចំពោះទុក្ខវេទនា ដែលជាហេតុឲ្យប្រព្រឹត្តទុច្ចរិតផ្សេងៗ, បុគ្គលនោះ រមែងទទួលផលនៃសេចក្ដីសុខចំរើន បើមិនប្រែចក៏គិតចុះខាន ។ ការអត់ធន់បែបនេះ ហៅថាអត់ធន់ចំពោះមោហៈ ។

ការបញ្ឈប់ទប់ចិត្តចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតលោភៈ ទោសៈ មោហៈ ដូចពោលមកហៅថាបិតៗ នេះ ជាគុណធ្វើឲ្យបុគ្គលអ្នកគ្រប់គ្រងផ្ទះ ឲ្យជាទីស្រឡាញ់ពេញចិត្តនៃជនច្រើនគ្នា, មិនឲ្យមានពៀរវេរាច្រើន មិនឲ្យមានទោសច្រើន មិនឲ្យភាំងភ្លេចស្មារតីក្នុងវេលាជិតស្លាប់, លុះស្លាប់ហើយទៅកាន់លោកខាងមុខ នឹងបានកើតក្នុងសុគតិភព ហេតុនោះ ទើបឈ្មោះថា យកក់សធម៌ ដោយប្រការដូច្នេះ ។

**ចាគៈ** – ការបំណាយទ្រព្យសម្បត្តិ ទំនុកបម្រុងព្រះពុទ្ធសាសនា កសាងសេនាសនៈ លើកថ្នល់ សង់ស្ពាន ជីកអណ្តូងទឹក សង់សាលា សម្រាប់បម្រើការសិក្សារៀនសូត្រ សង់មន្ទីរពេទ្យ សម្រាប់ព្យាបាលអ្នកជម្ងឺជាដើម ហៅថាចាគៈ ។

ពុទ្ធសាសនិកជន ជាអ្នកមានកតញ្ញូកតវេទី គោរពរាប់អានព្រះពុទ្ធ-សាសនា តែងតែបំណាយធនធានបូជាព្រះពុទ្ធសាសនា ដូចជាកសាងកុដិ - សាលា - វិហារជាដើម. ទើបឈ្មោះថាជាអ្នកគោរពចំពោះសាសនា យ៉ាងណា ប្រជាជនដែលជាពលរដ្ឋក្នុងប្រទេសនីមួយៗក៏យ៉ាងនោះដែរ គឺត្រូវតែបរិច្ចាគទ្រព្យបូជាជាកផតពលី មានបង់ពន្ធដារសម្រាប់ប្រទេសជាដើមទើបសមស័ក្តិខ្លួន ជាពលរដ្ឋរបស់ប្រទេស, តាំងអស់នេះក៏ហៅថា ចាគៈដែរ ។

ចាគៈនេះទុកជាស្នេហ៍មុខផ្ញើមនុស្សអ្នកនៅគ្រប់គ្រងផ្ទះ ឲ្យបានជាទីចាប់ចិត្តកប់អាននៃទៅតាមនឹងមនុស្សទាំងឡាយ ហេតុនោះទើបឈ្មោះថាឃរាវាសធម៌ ដោយប្រការដូច្នេះ ។

ធម៌ទាំង៤ប្រការនេះ បើមានបរិបូណ៌ក្នុងបុគ្គលឯណា បុគ្គលនោះតែងបានសេចក្ដីសុខ-ចំរើន រីកកាយមិនក្រៀមក្រំចិត្តក្នុងលោកនេះនឹងលោកខាងមុខដោយពិត ។ ព្រោះហេតុនោះបានជាព្រះទសពលទ្រង់សំដែងថាៈ

យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ
សច្ចំ ធមោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ
ឥង្ឃ អញ្ញេបិ បុច្ឆស្សុ បុថុ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ ។

" បុគ្គលដែលមានសទ្ធាគ្រប់គ្រងផ្ទះ ត្រូវមានធម៌ ៤ ប្រការនេះ គឺៈ សច្ចៈ (ការទៀងត្រង់) ១, ទមៈ (ការទូន្មាន) ១, ធិតិ (ការទប់ចិត្ត) ១, ចាគៈ (ការបរិច្ចាគ) ១, រមែងមិនសៅសោកក្នុងលោកខាងមុខដោយពិត, បើដូច្នោះ អ្នកចូរសួរសមណព្រាហ្មណ៍ឯទៀតឲ្យច្រើនគ្នាចុះ ក្រែងមានធម៌ណាក្នុងលោកនេះវិសេសជាង សច្ចៈ ទមៈ ចាគៈ ខន្តិ ទៅទៀត " ។

ធម៌មានសច្ចៈជាដើមនោះ ឈ្មោះថាឃរក្សធម៌គឺច្បាប់សម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ប្រតិបត្តិដើម្បីកុំឲ្យមានការប៉ះទង្គិចប្រេះឆា។ ច្បាប់សម្រាប់គផ្សារនូវសង្គមនីមួយៗឲ្យមានសាមគ្គី សេចក្ដីព្រមព្រៀងគ្នា ឲ្យមានសេចក្ដីគោរពកោតខ្លាចគ្នា មានទំនុកទុកចិត្តគ្នាជាបំផុត ។

ពណ៌នាធម្មកថាអំពីឃរក្សធម៌ ៤ យ៉ាង ក៏សូមសន្មតបញ្ចប់ត្រឹមប៉ុណ្ណេះ, សូមជូនពរចំពោះអស់លោក-អ្នកទាំងឡាយ ឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលគ្រប់ៗគ្នា ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា

សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ទាណិនោ

សត្វសត្វទាំងឡាយ ដែលដល់នូវសេចក្ដីទុក្ខ សូមឲ្យជាអ្នកឥតទុក្ខទៅ! ដែលដល់នូវភ័យ សូមឲ្យជាអ្នកឥតភ័យទៅ! ដែលដល់នូវសោក សូមឲ្យជាអ្នកបាត់សោកទៅ! ។

រតនត្តយតេជេន ភម្តោ ជរដ្ឋភិសំរោ

វុឌ្ឍី វិរុឡ្ហី បប្បោន្តុ សន្តិការញ្ញុ ឆាញ្ញថា

ដោយតេជៈនៃព្រះរតនត្រ័យ (ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ) សូមឲ្យប្រជាជនទាំងឡាយ អ្នកនៅក្នុងកម្ពុជរដ្ឋ ដល់នូវការល្អលាស់ចំរើន នឹងសន្តិភាព កុំបីឃ្លាតឆ្ងាយទៅជាមការដទៃឡើយ! ។